# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាអាទិត្យទី១នៃរដូវរង់ចាំនៅព្រះសហគមន៍សន្តសិលានិងសន្តប៉ូល
# ភ្នំពេញថ្មី ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៩
## ដើរក្រោមពន្លឺរបស់ព្រះជាម្ចាស់

**អត្ថបទទី១៖ អេសាយ ២,១-៥**

កូនចៅរបស់លោកយ៉ាកុបអើយ ចូរនាំគ្នាមក យើងដើរក្រោមពន្លឺរបស់ព្រះអម្ចាស់។ អស ២,៥

**អត្ថបទទី២៖ រ៉ូម ១៣,១១-១៤ក**

យប់ជិតផុតហើយ ហើយថ្ងៃក៏ជិតដល់ដែរ ដូច្នេះយើងត្រូវលះបង់អំពើនៃសេចក្តីងងឹតចោលទៅ ហើយប្រដាប់ខ្លួនដោយគ្រឿងសស្ត្រាវុធនៃពន្លឺវិញ។ រម ១៣,១២

**ដំណឹងល្អ៖ ម៉ាថាយ ២៤,៣៧-៤៤**

ចូរប្រុងស្មារតីឲ្យមែនទែន ដ្បិតអ្នករាល់គ្នាពុំដឹងថា ព្រះអម្ចាស់របស់អ្នករាល់គ្នានឹងមកដល់នៅពេលណាឡើយ។ មថ ២៤,៤២

បងប្អូនជាទីស្រឡាញ់!

យើងរៀបចំខ្លួនដើម្បីទទួលព្រះយេស៊ូដែលកំពុងយាងមក នៅក្នុងព្រះសហគមន៍របស់យើង នៅក្នុងដួងចិត្តរបស់យើង យើងធ្វើដូចម្តេចដើម្បីទទួលព្រះយេស៊ូដែលកំពុងយាងមក។ ឲ្យយើងភ្ញាក់ស្មារតីដើម្បីត្រៀមខ្លួន ដូចនៅក្នុងអត្ថបទទីមួយ "**ចាប់ពីពេលនេះតទៅ យើងដើរនៅក្រោមពន្លឺរបស់ព្រះអម្ចាស់**" យើងចេញពីភាពងងឹតនេះជាអត្ថន័យនៃរដូវរង់ចាំ។ យើងចេញពីភាពងងឹតបន្តិចម្តងៗយើងទៅដល់ពន្លឺ ដើម្បីឲ្យយើងពោរពេញដោយរស្មីមកពីព្រះជាម្ចាស់ យើងដើរក្រោមពន្លឺរបស់ព្រះអម្ចាស់។ "**ចាប់ពីពេលនេះតទៅប្រជាជាតិមួយឈប់ច្បាំងនឹងប្រជាជាតិមួយទៀត ហើយគេក៏លែងហាត់រៀនធ្វើសង្គ្រាមដែរ**" នៅទីក្រុងហ៊ីរ៉ូស៊ីម៉ា និងទីក្រុងណាហ្គាសាគីរបស់ប្រទេសជប៉ុន ជានិមិត្តរូបនៃសង្គ្រាមដ៏សាហាវនៅក្នុងពិភពលោកទាំងមូល។ នៅឆ្នាំ១៩៤៥ ក្នុងសង្គ្រាមពិភពលោកលើកទីពីរ សហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែកអាតូមិចលើទីក្រុងទាំងពីរនេះ ក្នុងរយៈពេលតែមួយវិនាទីធ្វើឲ្យវិនាសគ្មានសល់នៅជុំវិញមួយគីឡូម៉ែត្រ។ សប្តាហ៍មុនសម្តេចប៉ាបបានទៅដល់ទីក្រុងទាំងពីរហើយបាននិយាយប្រឆាំងនឹងអាវុធប្រល័យលោកយ៉ាងខ្លាំង។ សព្វថ្ងៃ យើងមានប្រទេសជាច្រើនដែលបានផលិតអាវុធទាំងនេះ ក្រោមរូបភាពដើម្បីការពារប្រទេសរបស់ខ្លួន ប៉ុន្តែគេនិយាយកុហក់គេផលិតដើម្បីរកស៊ីលក់ដូរ។ យើងរស់នៅក្នុងសង្គមមួយ ដែលការពារសុវត្ថិភាពផ្ទាល់ខ្លួនតែណែនាំឲ្យប្រទេសដទៃភ័យខ្លាច នេះមិនមែនជាការកសាងសុខសន្តិភាពទេ។

សេចក្តីសង្ឃឹមរបស់យើងគឺ "**ចាប់ពីពេលនេះតទៅប្រជាជាតិមួយឈប់ច្បាំងនឹងប្រជាជាតិមួយទៀត ហើយគេក៏លែងហាត់រៀនធ្វើសង្គ្រាមដែរ**" ឲ្យយើងចាប់ផ្តើមពីខ្លួនយើងកសាងសន្តិភាពនៅក្នុងដួងចិត្ត នៅក្នុងជីវិត នៅក្នុងគ្រួសារ នៅក្នុងសង្គម នៅក្នុងពិភពលោក។ យើងបង្កើតសង្គមមួយ ដែលចេះស្តាប់គ្នាទៅវិញទៅមកដើម្បីឲ្យពិភពលោករបស់យើងបន្តិចម្តងៗ ទៅជាពិភពថ្មីដែលមានសុខសន្តិភាពពិតប្រាកដ។ ថ្ងៃនេះ យើងបានធ្វើដំណើរនៅក្នុងរដូវរង់ចាំឲ្យយើងត្រៀមខ្លួន ដោយយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ដឹកនាំជីវិតរបស់យើង។ យើងស្វាគមន៍អ្នកតូចតាចដែលគ្មានទីពឹង យើងស្រឡាញ់គ្នាទៅវិញទៅមក ព្រះជាម្ចាស់យាងមកដើម្បីប្រទានពរដល់យើង។ យើងស្រឡាញ់នឹងបម្រើ នៅក្នុងជីវិតរបស់យើងព្រះជាម្ចាស់រង់ចាំមើលយើង ព្រះអង្គចង់ឲ្យយើងចេះបម្រើអ្នកដទៃដើម្បីឲ្យគេមានសេចក្តីសុខ។ ឲ្យយើងទុកចិត្តលើព្រះជាម្ចាស់ ដើម្បីទៅមុខបានឲ្យយើងអធិដ្ឋានសូមឲ្យយើងបានក្លាយទៅជាអ្នកដ៏វិសុទ្ធ។ អាម៉ែន៕